**គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចតំបន់ទន្លេសាប**

Tonle Sap Poverty Reduction and Smallholder Development Project

Loan: 2599/Grant: 0186-CAM ( SF )

# គោលការណ៍ណែនាំ

# ស្តីពី

# បច្ចេកទេសនៃការផលិតគ្រាប់ពូជស្រូវ

GUIDELINES

ON

TECHNIQUES OF RICE SEED PRODUCTION

**រៀបចំដោយ:ក្រុមការងារអនុវត្តគម្រោងនៃអគ្គនាយកដ្ឋានកសិកម្ម**

*ខែកក្កដា ឆ្នាំ ២០១៣*

# គោលការណ៍ណែនាំស្តីពី បច្ចេកទេសផលិតគ្រាប់ពូជស្រូវ

## ១.សេចក្តីផ្តើម

គម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប បានទទួលការគាំទ្រថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ក្នុងការអនុវត្តន៍គម្រោងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើរតួនាទីជាអ្នកដឹកនាំអនុវត្ត ហើយមានអគ្គនាយកដ្ឋានកសិកម្ម (GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខាធិការដ្ឋានជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៃក្រសួងមហាផ្ទៃ និងអាជ្ញាធរអភិវឌ្ឍន៍ បច្ចេកវិទ្យា និងលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន និងព័ត៌មានវិទ្យា (NiDA) នៃទីស្តីការគណៈរដ្ឋមន្ត្រី គឺជាអ្នកអនុវត្តផ្ទាល់។ តាមរយៈគម្រោងនេះ កសិករនៅក្នុងឃុំគោលដៅចំនួន ១៩៦ ឃុំ នៃស្រុកចំនួន ២៨ ក្នុងខេត្តគោលដៅចំនួន៤ គឺខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យនឹងអាចបង្កើនផលិតភាពកសិកម្ម និងមានទីផ្សារសម្រាប់ផលិតផលរបស់ពួកគាត់។ ការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អនឹងអាចបង្កើនផលិតភាព និងគុណភាពផលិតផលដំណាំកាន់តែល្អប្រសើរ។ ការជម្រុញឱ្យកសិករមានលទ្ធភាពប្រើប្រាស់គ្រាប់ពូជ សុទ្ធល្អមានលក្ខណៈទូលំទូលាយ ត្រូវការយន្តការផលិតគ្រាប់ពូជមួយដែលអាចធានាបាននូវគុណភាពខ្ពស់។ ដើម្បីមានគ្រាប់ពូជគ្រប់គ្រាន់សម្រាប់គម្រោង ការចងក្រង ការបណ្តុះបណ្តាល និងគាំទ្រក្រុមកសិករឬសហគមន៍ផលិតពូជនៅតាមស្រុក-ខេត្តគោលដៅ គឺជាគន្លឹះយ៉ាងសំខាន់មួយក្នុងចំណោមគន្លឹះសំខាន់ៗជាច្រើនទៀត។

ការបង្កើតគោលការណ៍ណែនាំបច្ចេកទេសផលិតកម្មគ្រាប់ពូជស្រូវ និងការចុះត្រួតពិនិត្យជាប្រចាំរបស់ មន្ត្រីអនុវត្តគម្រោង នឹងអាចជួយជម្រុញការផលិតគ្រាប់ពូជស្រូវនៅតាមសហគមន៍ទទួលបានជោគជ័យនិងមានគុណភាពល្អ។ ឯកសារនេះត្រូវបានចងក្រង ដោយផ្អែកលើឯកសារបច្ចេកទេសផលិតកម្មគ្រាប់ពូជរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា អង្គការអុីរីអន្តរជាតិ បទពិសោធន៍មកពីប្រទេសផ្សេងៗក្នុងតំបន់ និងការអនុវត្តជាក់ស្តែង ស្របតាមលក្ខខ័ណ្ឌនៃប្រទេសកម្ពុជា។ នៅក្នុងឯកសារនេះ យើងព្យាយាមបញ្ចូលនូវខ្លឹមសារសំខាន់ៗទាក់ទងនឹងសញ្ញាណទូទៅនៃគ្រាប់ពូជ ជំហានបន្តបន្ទាប់ដែលអនុវត្តក្នុងផលិតកម្មគ្រាប់ពូជផងដែរ។ ឯកសារនេះនឹងត្រូវប្រើប្រាស់ជាគោលសម្រាប់អ្នកបច្ចេកទេស និងក្រុមកសិករផលិតពូជស្រូវនៅតាមសហគមន៍ក្នុងគម្រោងកាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍កសិកម្មខ្នាតតូចនៅតំបន់ទន្លេសាប។

## ២. សញ្ញាណទូទៅនៃគ្រាប់ពូជ

### អ្វីទៅជាគ្រាប់ពូជស្រូវ?

គ្រាប់ពូជស្រូវគឺជាគ្រាប់មានជីវិត ដែលបានមកពីការជ្រើសរើសយ៉ាងហ្មត់ចត់ និងត្រឹមត្រូវទៅតាមបច្ចេកទេស។ ការប្រើប្រាស់គ្រាប់ពូជសុទ្ធល្អនឹងអាចជួយបង្កើនទិន្នផលស្រូវបានប្រមាណពី ៥-២០ភាគរយ។ គ្រាប់ពូជដែលល្អ មានលក្ខណៈដូចខាងក្រោមៈ

- មានភាពសុទ្ធខ្ពស់ គឺមិនលាយគ្រាប់ពូជស្រូវផ្សេងៗ និងគ្រាប់ស្មៅ
- គ្រាប់ពូជមិនមានផ្ទុកនូវជំងឺ ឬភ្នាក់ងារបង្ករោគផ្សេងៗ និងការបំផ្លាញរបស់សត្វល្អិត
- គ្រាប់ពូជមានសំបុរថ្លាល្អ និងគ្រាប់អង្ករមិនប្រេះស្រាំ ឬបាក់
- គ្រាប់ពូជមានដំណុះខ្ពស់ (ខ្ពស់ជាង ៨៥ភាគរយ) និងលូតលាស់ខ្លាំង
- គ្រាប់ពូជមានសំណើមទាប (១២-១៤ភាគរយ)
- ស្រូវពូជមិនមានលាយសំដីច្រើន (មិនលើសពី ២ភាគរយ)
- ស្រូវពូជមានគ្រាប់ពេញល្អ និងមានឯកសណ្ឋានភាព (ប្រវែង ទំហំ និងពណ៌សំបុរ ។ល។)
- ស្រូវពូជនៅរក្សាបាននូវលក្ខណៈសេនេទិកដើម។

### តើគេចាត់ថ្នាក់គ្រាប់ពូជស្រូវយ៉ាងដូចម្តេច?

គេចែកគុណភាពគ្រាប់ពូជស្រូវជា ៤ ចំណាត់ថ្នាក់ ដូចខាងក្រោមៈ

- គ្រាប់ពូជសុទ្ធជម្រើសវិទូៈ (Breeder seed)ៈ ត្រូវបានផលិតឡើងដោយអ្នកបង្កាត់ពូជ ហើយគ្រាប់ពូជនេះតំណាងឱ្យខ្សែស្រឡាយពិតប្រាកដនៃប្រភេទពូជនីមួយៗ។ គេប្រើប្រាស់វាសម្រាប់ផលិតគ្រាប់ពូជសុទ្ធគ្រឹះ។
- គ្រាប់ពូជសុទ្ធគ្រឹះ (Foundation seed)ៈ ត្រូវបានផលិតឡើងដោយអ្នកបង្កាត់ពូជ។ គេប្រើប្រាស់វាសម្រាប់ផលិតគ្រាប់ពូជសុទ្ធទទួលស្គាល់។
- គ្រាប់ពូជសុទ្ធទទួលស្គាល់ (Registered seed)ៈ ត្រូវបានផលិតឡើងដោយមន្ត្រីបច្ចេកទេស ឬអ្នកបច្ចេកទេសនៅតាមស្ថានីយ៍។ គេប្រើប្រាស់វាសម្រាប់ផលិតគ្រាប់ពូជសុទ្ធអនុញ្ញាត។
- គ្រាប់ពូជសុទ្ធអនុញ្ញាត (Certified seed)ៈ ត្រូវបានផលិតឡើងដោយមន្ត្រីបច្ចេកទេស ឬអ្នកបច្ចេកទេសនៅតាមស្ថានីយ៍។ គេប្រើប្រាស់វាសម្រាប់ផលិតគ្រាប់ពូជសុទ្ធល្អ។
- គ្រាប់ពូជសុទ្ធល្អ (Good seed/commercial seed) ៈ ត្រូវបានផលិតឡើងដោយមន្ត្រីបច្ចេកទេស ក្រុមហ៊ុន ឬកសិករនៅតាមសហគមសម្រាប់ផ្សាព្វផ្សាយ ឬធ្វើពាណិជ្ជកម្ម។

## តារាងចំណាត់ថ្នាក់គ្រាប់ពូជស្រូវនៅប្រទេសកម្ពុជា

| កត្តាផ្សេងៗ | គ្រាប់ពូជសុទ្ធគ្រឹះ | គ្រាប់ពូជសុទ្ធ ទទួលស្គាល់ | គ្រាប់ពូជសុទ្ធអនុញ្ញាត |
|---|---|---|---|
| ភាពសុទ្ធ (%) | ៩៨ | ៩៨ | ៩៧ |
| គ្រាប់ពូជលាយ/៥00g | ២ | ៥ | ១0 |
| គ្រាប់ស្មៅនិងដំណាំផ្សេងៗ (%) | 0 | 0,0៥ | 0,១ |
| សារធាតុលាយឡំ (%) | ២ | ២ | ៣ |
| ស្រូវពណ៌ក្រហម / ៥00g | 0 | ១ | ២ |
| អត្រាដំណុះទាបបំផុត (%) | ៨៥ | ៨៥ | ៨៥ |
| អត្រាសំណើម (%) | ១៤ | ១៤ | ១៤ |

## តើកសិករនឹងទទួលបានផលចំណេញអ្វីខ្លះ ពីការប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ?

- ធ្វើឱ្យកសិករកាត់បន្ថយបាននូវបរិមាណគ្រាប់ពូជសំរាប់ដាំដុះ
- ធ្វើឱ្យអត្រាគ្រាប់ពូជដុះក្នុងស្រែបានខ្ពស់ជាអតិបរមា
- ធ្វើឱ្យកសិករកាត់បន្ថយការព្រោះគ្រាប់ពូជសារឡើងវិញ ដោយសារដំណុះគ្រាប់ទាប
- ធ្វើឱ្យសំណាប ឬដើមស្រូវដុះលូតលាស់ខ្លាំងល្អ
- ធ្វើឱ្យដំណាំស្រូវក្នុងស្រែដុះមានឯកសណ្ឋានភាព
- ធ្វើឱ្យកំរិតលូតលាស់លឿន និងភាពធន់ទ្រាំនឹងជំងឺនិងសត្វល្អិតកាន់តែខ្លាំង
- ធ្វើឱ្យដំណាំស្រូវទុំស្រុះគ្នាល្អ
- ធ្វើឱ្យស្រូវអង្ករមានគុណភាពខ្ពស់ ( មិនលាយគ្រាប់ពូជផ្សេង និងគ្រាប់ស្មៅចង្រៃ)
- ធ្វើឱ្យតម្លៃស្រូវអង្ករមានតម្លៃខ្ពស់នៅលើទីផ្សារ

## តើកត្តាអ្វីខ្លះដែលជះឥទ្ធិពលដល់គុណភាពគ្រាប់ពូជ?

កត្តាសំខាន់ៗដែលមានឥទ្ធិពលដល់គុណភាពគ្រាប់ពូជក្នុងផលិតកម្មគ្រាប់ពូជរួមមាន៖

- ការប្រើប្រាស់គ្រាប់ពូជមេសំរាប់ដាំដុះពង្រីកពូជ
- វត្តមាននៃគ្រាប់ពូជផ្សេងនៅក្នុងស្រែ
- លក្ខណៈបរិស្ថានជួបប្រទះក្នុងកំឡុងពេលផលិត
- ការប្រើប្រាស់ជីនៅពេលផលិត

- ការបំផ្លាញដោយសត្វ និងជំងឺនៅពេលផលិត
- ពេលវេលានៃការប្រមូលផល
- ការប្រើប្រាស់ឧបករណ៍នៅពេលប្រមូលផល
- ការហាលសំងួត
- ការដឹកជញ្ជូន និងការបកសំអាត
- សំណើម និងសីតុណ្ហភាពនៅពេលស្តុកគ្រាប់ពូជ
- ការបំផ្លាញដោយសត្វល្អិតក្នុងស្តុក
- ការវេចខ្ចប់ និងចែកចាយគ្រាប់ពូជ

# ៣. ផលិតកម្មស្រូវពូជ

## ៣.១ ទីតាំងផលិតស្រូវពូជ និងការជ្រើសរើសពូជ

ទីតាំងដែលត្រូវជ្រើសរើសក្នុងការធ្វើផលិតកម្មគ្រាប់ស្រូវពូជ ត្រូវមានលក្ខណៈ ដូចតទៅ ៖

- មានប្រព័ន្ធស្រោចស្រព និង មានប្រភពទឹកគ្រប់គ្រាន់ សំរាប់ស្រោចស្រព គ្រប់រដូវ ។
- ផ្ទៃដីមានសណ្ឋានរាបស្មើ មានភ្លឺងាយស្រួលដល់ការគ្រប់គ្រងទឹក និង ជីជាតិដី ។
- ស្គាល់ពីប្រវត្តិពូជស្រូវ ឬ ឈ្មោះពូជដែលបានដាំពីរដូវមុន ។
- មានទំហំផ្ទៃដីសមស្របទៅនិងបរិមាណគ្រាប់ពូជដែលត្រូវការ

ដោយឡែកការជ្រើសរើសពូជស្រូវសម្រាប់ដាំដុះវិញ គួររើសពូជណាដែលផ្តល់ទិន្នផលខ្ពស់ និងអង្គរឆ្លើយតបទៅនឹងតំរូវការទីផ្សារ ។

## ៣.២ ដំណើរការត្រួតពិនិត្យផលិតកម្មស្រូវពូជ

មានប្រទេសជាច្រើនមុននឹងបញ្ជាក់ថាគ្រាប់ពូជ គេត្រូវត្រួតពិនិត្យជាមុននៅពេលមុនប្រមូលផល ។ តំណាងអ្នកបញ្ជាក់គុណភាពគ្រាប់ពូជចុះត្រួតពិនិត្យស្រែយ៉ាងតិចម្តងនៅក្នុងដំណាក់កាលលូតលាស់ និងម្តងទៀតនៅដំណាក់កាលទុំ មុនពេលប្រមូលផល ។ ស្រែខ្លះមិនអាចទទួលយកសម្រាប់ធ្វើពូជបានទេ ប្រសិនបើពិនិត្យឃើញថាក្នុងស្រែនោះមានដុះពូជផ្សេងៗច្រើន មានស្មៅដុះច្រើន មានការលូតលាស់ខ្សោយ មានកើតជំងឺច្រើន មានការបំផ្លាញច្រើនដោយសត្វល្អិត និងមិនមានភាពច្បាស់លាស់អំពីលក្ខណៈសំគាល់អត្តសញ្ញាណដូចទៅនឹងពូជមេ ។ ទាំងអស់ខាងលើ អាចនិយាយបានថាវាទាក់ទងនឹង គុណភាពនៃការគ្រប់គ្រងនៅទីវាល (Field Management) ។ ក្រៅពីការត្រួតពិនិត្យនៅទីវាល ការគ្រប់គ្រង និងត្រួតពិនិត្យក្រោយពេលប្រមូលផល (Post Harvest Management) ក៏ចាំបាច់ត្រូវធ្វើផងដែរ ។

## ៣.៣ ការគ្រប់គ្រងនៅទីវាល

### ៣.១.១ ការពារការដុះលាយពូជផ្សេង

មានកត្តាសំខាន់ៗចំនួន ២ ដែលអាចធ្វើឱ្យមានវត្តមានពូជផ្សេងក្នុងស្រែ គឺ

**ទី១. ការប្រើប្រាស់គ្រាប់ពូជមិនសុទ្ធ:** ដើម្បីចៀសវាងកត្តានេះ អ្នកផលិតគ្រាប់ពូជត្រូវច្បាស់ថា គ្រាប់ពូជដែលប្រើប្រាស់សំរាប់ផលិតឬដាំពង្រីកពូជត្រូវមាន ចំណាត់ថ្នាក់ខ្ពស់ជាងគ្រាប់ពូជ ដែលយើងគ្រោងនឹងផលិត។ ត្រង់ចំណុចនេះនឹងមានសំណួរមួយអាចចោទសួរទៀតថា **ប្រសិនបើគ្រាប់ពូជដែលយកមក ប្រើប្រាស់មានចំណាត់ថ្នាក់ ទាបជាងគ្រាប់ពូជសុទ្ធអនុញ្ញាត (ប្រើប្រាស់បាន ២-៣ ជំនាន់ហើយ) តើ អាចហៅថាគ្រាប់ពូជសទ្ធល្អបានទៀតទេ?** ចម្លើយ គឺថា យើងនៅតែអាចអាចហៅគ្រាប់ពូជសុទ្ធល្អបានដដែល ប្រសិនបើពិនិត្យ ឃើញថាភាពសុទ្ធរបស់វានៅតែខ្ពស់។

**ទី២. វត្តមានគ្រាប់ពូជប្រភេទផ្សេងក្នុងស្រែ:** ការផ្លាស់ប្តូរពូជផ្សេងគ្នាពីរដូវមុន ជាមូលហេតុធំបំផុតដែលធ្វើឱ្យមានវត្តមានគ្រាប់ពូជផ្សេងច្រើននៅក្នុងស្រែផលិតពូជ។ ប្រសិនបើមិនបានសំអាតគ្រាប់ដែលជ្រុះទាំងនោះទេ ទោះបីយើងប្រើប្រាស់នូវគ្រាប់ពូជចំណាត់ថ្នាក់ល្អយ៉ាងណាក៏ដោយ យើងនៅតែឃើញមានដុះលាយនូវពូជចាស់ នោះក្នុងស្រែផលិតពូជដដែល ព្រោះគ្រាប់ស្រូវឬស្រូវមួរអាចដុះឡើងវិញជាធម្មតា។ ត្រង់ចំណុចនេះនឹងមានសំណួរមួយចោទសួរថា **បើដីខ្ញុំកំពុងដាំពូជផ្សេងតើនៅរដូវក្រោយ ខ្ញុំអាចប្រើប្រាស់ដីនេះសំរាប់ផលិត ឬពង្រីកពូជផ្សេងបានដែរឬទេ?** ចម្លើយគឺថា អ្នកអាចផលិតពូជស្រូវផ្សេងៗទៀតបាន ប្រសិនបើអ្នកបានសំអាតអស់ជាអតិបរមានូវគ្រាប់ពូជផ្សេង និងសំណល់ពូជដែលអ្នកកំពុងដាំ។ សំណួរអាចនឹងលើកឡើងទៀតថា **តើធ្វើដូចម្តេចទើបអាច សំអាតគ្រាប់ជ្រុះក្នុងស្រែឱ្យអស់?** គឺត្រូវភ្ជួរដីស្រែហាលថ្ងៃ ឬទុកដីឱ្យទំនេររយៈពេលពី ១០-១៥ថ្ងៃ រួចបញ្ចូលទឹកឱ្យសើម ដើម្បីឱ្យគ្រាប់ស្មៅ និងគ្រាប់ស្រូវជ្រុះក្នុងស្រែដុះ រួចធ្វើការកំចាត់។

ម្យ៉ាងទៀតយើងកអាចប្រើប្រាស់វិធីសាស្ត្រដាំដុះដោយស្ទូងដើម្បីងាយស្រួលក្នុងការកំចាត់ពូជលាយ (ដុះខុសជួរ ជាពូជលាយ)។ ត្រង់ចំណុចនេះ គេអាចលើកជាសំណួរថា **តើផលិតកម្មគ្រាប់ពូជ ចាំបាច់ត្រូវអនុវត្តដោយស្ទូងឬយ៉ាងណា?** ចម្លើយគឺថា សំរាប់ការផលិតគ្រាប់ពូជសុទ្ធគ្រឹះ ពូជសុទ្ធទទួលស្គាល់ និងគ្រាប់ពូជសុទ្ធអនុញ្ញាត ទាមទារការដាំដុះ ដោយស្ទូង។ ដោយឡែក ការផលិតគ្រាប់ពូជសុទ្ធល្អ គឺអាចធ្វើបាន **ដោយឧបករណ៍ដាំគ្រាប់ (Drum Seeder)** ឬព្រោះដោយដៃ តែវិធីសាស្ត្រទាំងពីរនេះ ត្រូវការរៀបចំដីឱ្យបានល្អ និងសំអាតគ្រាប់លាយក្នុងស្រែជាមុនសិន ហើយត្រូវជួបប្រទះនឹងបញ្ហាពិបាកពិនិត្យ និងកាត់ពូជលាយ។

***ទី៣. ការប្រើប្រាស់បច្ចេកទេសសមស្រប:*** ក្រៅពីការប្រើប្រាស់គ្រាប់ពូជសុទ្ធគុណភាពល្អ និងការសំអាតគ្រាប់លាយក្នុងស្រែ មានចំណុចសំខាន់ៗចំនួន ៧ ដែលអ្នកផលិតគ្រាប់ពូជស្រូវគួរគិតពិចារណាគឺ:

- ការរៀបចំដី

- ការសាបព្រោះដកស្ទូង

- ការប្រើប្រាស់ជី

- ការគ្រប់គ្រងទឹក

- ការគ្រប់គ្រងស្មៅចង្រៃនិង សមាសភាពចង្រៃផ្សេងៗ

- ការកាត់ពូជលាយ

- ការប្រមូលផល

ជារួម បច្ចេកទេសដាំដុះក្នុងផលិតកម្មគ្រាប់ពូជ គឺមិនខុសគ្នានឹងការធ្វើផលិតកម្មនោះទេ។ ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបរួម ស្តីពីការអនុវត្តបច្ចេកទេសសមស្របសម្រាប់ផលិតកម្មស្រូវពូជ។

✓ **ការរៀបចំដី:** ការរៀបចំដីមានឥទ្ធិពលយ៉ាងខ្លាំងលើការលូតលាស់របស់ដំណាំស្រូវ។ ការភ្ជួរលប់ស្មៅនិងគល់ជញ្ជ្រាំង គឺធ្វើឱ្យដីស្រែផុសល្អ និងមានរន្ធខ្យល់ច្រើន ដែលអាចជួយសម្រួលដល់ការលូតលាស់របស់ប្រព័ន្ធឬស និងបង្កើនជីជាតិដី។ ការភ្ជួរលាស់និងហាលដីបាន ល្អធ្វើឱ្យងាប់ស្មៅចង្រៃ ជាពិសេសអាចសម្លាប់ពពួកផ្សិត សម្លាប់ពងដឹកឡើនិងសត្វល្អិតសេសសល់ក្នុងស្រែ។ ជាទូទៅ ដីស្រែ ត្រូវភ្ជួរឱ្យបានសព្វល្អ ភ្ជួរឱ្យបានជំរៅពី ១៥-២០ស.ម ចំនួនពី ២-៣ដង រាស់និងកៀរពង្រាបដីឱ្យបានរាបស្មើល្អ។ ការពង្រាបដី បានល្អធ្វើឱ្យងាយស្រួលបញ្ចេញបញ្ចូលទឹក និងធ្វើឱ្យជីរត់ស្មើរល្អក្នុងស្រែ។

✓ **ការសាបព្រោះ និងដកស្ទូង:** សម្រាប់ការផលិតពូជដោយស្ទូង យើងគប្បីប្រើប្រាស់សំណាបដែលមានសុខភាពល្អ។ ដើម្បីទទួលបានសំណាបសុខភាពល្អ គួរគប្បីធ្វើថ្នាលសំណាបឱ្យបានល្អ ឬធ្វើថ្នាលដាប៉ុកតែម្តង ដើម្បីងាយស្រួលថែទាំ និងដឹកជាញ្ជូនទៅស្ទូង។ សំរាប់ថ្នាលដាប៉ុក កសិករអាចប្រើប្រាស់កៅស៊ូផ្លាស្ទិកទ្រាប់ពីក្រោម ឬស្លឹកចេក ដោយលាយដីជី (ដី ៤០% ជីកំប៉ុស្ត ៤០% និងផេះអង្កាម២០%) កំរាស់ប្រមាណ៣ស.ម។ ក៏រិតគ្រាប់ពូជដែរប្រើលើថ្នាលធម្មតាគឺ ០.១គ.ក្រក្នុង១ម៉ែត្រការ៉េ និងថ្នាលដាប៉ុក ០.៥គ.ក្រក្នុង ១ម៉ែត្រ ការ៉េ។ អាយុសំណាបសមរម្យដែលអាចយកទៅស្ទូងបាន គឺពី ១៣-១៥ថ្ងៃឡើង។ ជាការល្អ កសិករគួរស្ទូងសំណាបខ្ចី ដើម្បីឱ្យបែកគុម្ពបានច្រើន។ តើធ្វើដូចម្តេចដើម្បីមានសំណាបខ្ចីសំរាប់ស្ទូង ប្រសិនបើរដូវរាំងស្ងួតអូសបន្លាយ? ចម្លើយ គឺថាយើងអាចធ្វើបាន ដោយផ្លាស់ប្តូរទំលាប់ពីការសាបរង់ចាំទឹកភ្លៀង មកជាការរៀបចំដីរង់ចាំសំណាបវិញ។ នេះមានន័យថា នៅពេលមានទឹកភ្លៀង កសិករត្រូវភ្ជួររាស់ដីឱ្យបានជាស្រេច ហើយពេលមានទឹកភ្លៀងគ្រប់គ្រាន់ ទើបចាប់ផ្តើមសាបសំណាប។ ជាការល្អ ត្រូវស្ទូងភ្លាមបន្ទាប់ពីដករួច ដោយជៀសវាងការផ្អាប់រយៈពេលយូរមុននឹងយកទៅស្ទូង។

ចំពោះអាយុសំណាបដែលអាចដកទៅស្ទូងបាន វាប្រែប្រួលទៅតាមប្រភេទពូជដូចបញ្ជាក់ខាងក្រោម :

- ស្រូវស្រាល អាយុសំណាប ពី ១៥ ទៅ ២០ ថ្ងៃ

- ស្រូវកណ្តាលមិនប្រកាន់រដូវ អាយុសំណាប ពី ២០ ទៅ ២៥ ថ្ងៃ

- ស្រូវកណ្តាលប្រកាន់រដូវ អាយុសំណាប ពី ២៥ ទៅ ៣០ ថ្ងៃ
- ស្រូវធ្ងន់ប្រកាន់រដូវ អាយុសំណាប ពី ៣០ ទៅ ៣៥ ថ្ងៃ

ដោយឡែក ចំពោះចន្លោះគុម្ពស្ទូងវិញ គឺប្រែប្រួលទៅ តាមប្រភេទដី អាយុកាលសំណាប និងពេលវេលាដាំដុះ (ស្រូវប្រកាន់រដូវ)។ ចន្លោះគុម្ពជាមធ្យម (១៥ស.ម x ១៥ស.ម) សម្រាប់ដីមិនសូវសំបូរជីជាតិ អាយុសំណាបចាស់ និងពេលវេលាបែកគុម្ពនៅខ្លី ហើយចន្លោះគុម្ព (២០ស.ម x ២០ស.ម) អាច ប្រើសម្រាប់ដីមានជីជាតិ សំណាបខ្ចី និងពេលវេលាបែកគុម្ពនៅវែង។

✓ **ការប្រើប្រាស់ជី:** ដំណាំស្រូវក៏ដូចជាដំណាំផ្សេងៗដែរ គឺត្រូវការសារធាតុចិញ្ចឹមចំនួន ១៦មុខ គឺ N, P, K, S, Zn, Fe, Mn, Ca, Mg, Cl, C, B, Cu, Mo, H, O។ ក្នុងចំណោមសារធាតុ ចិញ្ចឹមទាំង ១៦ មុខនេះ ដំណាំស្រូវត្រូវការ N, P, K ច្រើនជាងគេ ហើយសារធាតុចិញ្ចឹមទាំងនេះមានលក់នៅទីផ្សារក្នុងទំរង់ជាជីគីមី និងសារធាតុផ្សេងៗមានក្នុងជីធម្មជាតិ។ ការផ្តល់សារធាតុចិញ្ចឹមគ្រប់គ្រាន់ ធ្វើឱ្យដំណាំស្រូវបែកគុម្ពបានច្រើន ផលិតកួរបានវែង ផលិតគ្រាប់បានច្រើន និងបង្កើនភាគរយគ្រាប់ពេញបានច្រើន (គ្រាប់ថ្លោសល្អ) និងទិន្នផលខ្ពស់។ លើសពីនេះទៀត ការប្រើប្រាស់ជីបានត្រឹមត្រូវក៏អាចជួយជំរុញគុណភាពអង្ករបានល្អប្រសើរ ហើយគ្រាប់ពូជមានដំណុះលឿនផងដែរ។ ផ្ទុយទៅវិញ ការប្រើប្រាស់ជីមិនគ្រប់គ្រាន់ ឬលើសពីតម្រូវការក៏ធ្វើឱ្យដំណាំស្រូវកើតមានជំងឺផងដែរ ជាពិសេសការប្រើប្រាស់ជី N តែម្តង។ ជាអនុសាសន៍ កសិករគួរប្រើប្រាស់ជីឱ្យបានត្រឹមត្រូវតាមបច្ចេកទេស គឺត្រូវគិតគូរអំពីប្រភេទដី ដំណាក់កាលលូតលាស់របស់ដំណាំស្រូវ ប្រភេទជី ក៏រិតជីដែលគួរប្រើប្រាស់ សំអាតស្មៅពីស្រែជាមុន និងត្រូវមានទឹកក្នុងស្រែ។ បច្ចុប្បន្នមានប្រភេទជីច្រើនមុខកំពុងចរាចរលក់លើទីផ្សារក្នុងប្រទេសកម្ពុជាដូចជា ជីទោល ជីសមាស ជីទឹក និងជីសរីរាងផ្សេងៗ។ តើកសិករគួរប្រើប្រាស់ប្រភេទ ជីណាមួយសំរាប់ផលិតកម្មដំណាំស្រូវ?

សម្រាប់ស្រែផលិតពូជ គប្បីប្រើប្រាស់ជីធម្មជាតិឱ្យបានច្រើនសំរាប់ទ្រាប់បាត **(៣-១០តោន ក្នុង១ហិកតា)**។ ចំពោះជីគីមីវិញ គួរប្រើជីផូស្វ័រ (P) សំរាប់ទ្រាប់បាត ១០០% (ស្រូវសន្ទូង) ឬប្រើក្រោយព្រោះរយៈពេល ១៥ថ្ងៃក្រោយដាំ (ស្រូវពង្រោះ) ហើយជីអ៊ុយរ៉េ (N) និងប៉ូតាស្យូម (K) សំរាប់បំប៉នក្នុងដំណាក់កាលបែកគុម្ព ៥០% និងពេលកកើតកួរ ៥០%។

ក្នុងករណីពិបាកក្នុងការលាយជីសំរាប់បាច កសិករអាចប្រើប្រាស់ជី N-P-K សុទ្ធតែម្តងក៏បាន គឺជី ២០-២០-១៥ +២TE ឬជី ២៧-២០-៨+២TE ក្នុងក៏រិត ៤-៦បាវ ក្នុងមួយហិកតា ដោយបែងចែកជា ៣-៤ដំណាក់ ទៅតាមសភាពលូតលាស់របស់ដំណាំស្រូវ។

✓ **ការគ្រប់គ្រងទឹក:** ទឹកជាធនធានចាំបាច់ក្នុងផលិតកម្មដំណាំស្រូវ។ វាដើរតួនាទីដ៏សំខាន់ នៅក្នុងដំណើរលូតលាស់របស់ដំណាំដូចជា ធ្វើឱ្យរុក្ខជាតិធន់នឹងកំដៅតាមរយៈការ បំភាយចំហាយទឹកចេញពីផ្ទៃស្លឹក ជាភ្នាក់ងារក្នុងដំណើរស្មើសំយោគ សម្របសម្រួលដល់ការស្រូបនិងដឹកជញ្ជូនសារធាតុចិញ្ចឹម។ ម្យ៉ាងទៀត កំពស់ទឹកក្នុង ស្រែមានទំនាក់ទំនងទៅនឹង

លទ្ធភាពបែកគុម្ពរបស់ស្រូវ និងការ លូតលាស់របស់ស្មៅចង្រៃ។ ដូច្នេះ ការគ្រប់គ្រងទឹក គឺជាកត្តាចំបងដែលកសិករត្រូវយកចិត្តទុកដាក់ក្នុងផលិតកម្មដំណាំស្រូវ ។ នៅក្នុងដំណាក់កាលបែកគុម្ព គួររក្សាទឹកក្នុងស្រែកំពស់ប្រមាណ ២-៥ស.ម នៅក្នុងកំឡុងពេលវគ្គលូតលាស់ ដើម្បីឱ្យប្រព័ន្ធឫសរបស់ស្រូវលូតលាស់ល្អ និងបែកគុម្ពច្រើន។ ចាប់ពីដំណាក់កាលកកើតកួរដល់ដំណាក់កាលដាក់ទឹកដោះ ស្រូវត្រូវការទឹកជាប្រចាំ ដើម្បីបង្កើនសមាសភាពទិន្នផល។ ដូច្នេះ កសិករត្រូវថែរក្សាទឹកក្នុងស្រែយ៉ាងហោចណាស់ពី ៥-១០ស.ម ជាពិសេសនៅចុងរដូវវស្សា ។

✓ **ការគ្រប់គ្រងស្មៅចង្រៃ:** ស្មៅចង្រៃ គឺជាប្រភេទរុក្ខជាតិទាំងឡាយណាដែលដុះលាយជាមួយស្រូវ ហើយយើងមិនត្រូវការ។ ស្មៅចង្រៃមានឥទ្ធិពលអវិជ្ជមានដល់ដំណាំស្រូវដូចជា ប្រជែងស្រូបយកសារធាតុចិញ្ចឹម ពន្លឺព្រះអាទិត្យ និងទឹកព្រម ទាំងជាជំរកសត្វល្អិតចង្រៃ ជំងឺបំផ្លាញដំណាំស្រូវ និងធ្វើឱ្យគ្រាប់ស្មៅលាយក្នុងគ្រាប់ពូជ ទៀតផង។ ដើម្បីគ្រប់គ្រងស្មៅចង្រៃប្រកបដោយប្រសិទ្ធភាព កសិករគួរអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម:

១. ត្រូវសំអាតគ្រាប់ស្មៅឱ្យបានស្អាតពីក្នុងគ្រាប់ពូជស្រូវមុននឹងយកទៅដាំ

២. រៀបចំដីស្រែឱ្យបានស្អាតល្អ (ភ្ជួររាស់ និងហាលដី) និងពង្រាបដីឱ្យបានស្មើល្អ

៣. រក្សាទឹកក្នុងស្រែឱ្យបានជាប្រចាំ

៤. ធ្វើស្មៅ យ៉ាងតិចឱ្យបាន ២ដង ក្នុងដំណាក់កាលបែកគុម្ព (១៥ថ្ងៃក្រោយស្ទូង និង៣០ថ្ងៃក្រោយស្ទូង)

៥. សម្រាប់ស្រូវពង្រោះ ការប្រើប្រាស់ថ្នាំសំលាប់ស្មៅបន្ទាប់ពីព្រោះបាន ២-៣ថ្ងៃ និង១៥ថ្ងៃក្រោយព្រោះ គឺមានប្រសិទ្ធភាពខ្ពស់បំផុត ។

✓ **ការគ្រប់គ្រងសត្វល្អិត និងជំងឺ:** ការបំផ្លាញដោយសត្វល្អិត និងជំងឺលើដំណាំស្រូវគឺប៉ះពាល់យ៉ាងខ្លាំងដល់គុណភាពគ្រាប់ពូជ។ សត្វបំផ្លាញដំណាំស្រូវសំខាន់ៗមានដូចជា សត្វទ្រីប មមាចជញ្ជក់ដើម មមាចជញ្ជក់ស្លឹក ដង្កូវបំពង់កាត់ស្លឹក ដង្កូវស៊ីរូងដើម ដង្កូវមូរស្លឹក ស្រឹងជញ្ជក់ ទឹកដោះ សង្កើចខ្មៅ ខ្យងពណ៌មាស និងកណ្តុរ។ល។ ក្នុងចំណោមសត្វស៊ីដំណាំទាំងនេះ ពពួកមមាច ស្រឹងជញ្ជក់ទឹកដោះ ដង្កូវ មូរស្លឹក និងកណ្តុរ ធ្វើឱ្យទិន្នផលស្រូវថយចុះខ្លាំងជាងគេ។ ការប្រើប្រាស់វិធានការទាំងប្រាំរបស់ IPM គឺធ្វើឱ្យកសិករចំណេញថវិកា និងមិនប៉ះពាល់ដល់បរិស្ថាន និងសុខភាព។ វិធានការទាំង ០៥ របស់ IPM មានដូចខាងក្រោម:

ទី១: វិធានការដាំដុះ (ការជ្រើសរើសពូជ ការរៀបចំដី បច្ចេកទេសដាំដុះ ការគ្រប់គ្រងទឹក ....)

ទី២: វិធានការជីវសាស្ត្រ (ប្រើប្រាស់នូវភ្នាក់ងារមានជីវិតមានប្រយោជន៍ ដើម្បីទប់ស្កាត់ ឬកំចាត់ភ្នាក់ងារចង្រៃ)

ទី៣: វិធានការមេកានិច (ប្រើនូវកំលាំងមនុស្សដើម្បីកំចាត់ ដូចជាបំបែកសំបុកពង ដង្កូវ និងមេចំណាស់...)

ទី៤: វិធានការរូបសាស្ត្រ (ប្រើប្រាស់នូវអន្ទាក់ភ្លើង ការប្រើប្រាស់ក្រដាសព័ណ៌ស្អិត...)

ទី៥: វិធានការគីមីសាស្ត្រ( ការប្រើប្រាស់ថ្នាំពុលកសិកម្ម ដើម្បីកំចាត់ភ្នាក់ងារចង្រៃ)

ជាគោលការណ៍ដើម្បីគ្រប់គ្រងសត្វល្អិតប្រកបដោយប្រសិទ្ធភាព កសិករត្រូវត្រួតពិនិត្យវត្តមានសត្វស៊ីដំណាំ និងវត្តមានសត្វមានប្រយោជន៍ក្នុងស្រែឱ្យបានជាប្រចាំ ជាពិសេសក្រោយពេលប្រើប្រាស់ជីបំប៉នរយៈពេលមួយសប្តាហ៍។ ក្នុងករណីមានសត្វបំផ្លាញដំណាំផ្ទុះរាលដាល ហើយវាលវិធានការខាងលើមិនអាចទប់ស្កាត់បាន កសិករត្រូវប្រើវិធានការគីមីដែលជាជម្រើសចុងក្រោយ តែត្រូវអនុវត្តទៅតាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ ដោយធ្វើការពិភាក្សាជាមុនជាមួយមន្ត្រីជំនាញ។ ទន្ទឹមនឹងនោះកសិករត្រូវគិតគូរ ដល់សុវត្ថិភាពផ្ទាល់ខ្លួន ក្រុមគ្រួសារ អ្នកជិតខាង សត្វពាហនៈ និងប្រព័ន្ធបរិស្ថាន។

ចំពោះជំងឺសំខាន់ៗលើដំណាំស្រូវមានដូចជា ជំងឺអុចត្នោត ប្លួស រលាកនិងរលួយស្រទបស្លឹក ដែលធ្វើឱ្យគុណភាពគ្រាប់ពូជធ្លាក់គុណភាព។ ជំងឺទាំងនេះ គឺបង្កឡើងដោយពពួកផ្សិត ដែលបណ្តាលមកពីការប្រើប្រាស់ជីមិនមានតុល្យភាព (លើសឬខ្វះសារធាតុអាសូត)។ ដើម្បីជៀសផុតពីជំងឺទាំងនេះ ក្នុងផលិតកម្មគ្រាប់ពូជ កសិករគួរប្រើប្រាស់ថ្នាំផ្សិតដើម្បីការពារ នៅក្នុងដំណាក់កាលផើម និងចេញកួរ ឬដំណាក់កាលដាក់ទឹកដោះ។ ថ្នាំការពារ និងព្យាបាលជំងឺផ្សិតទាំងនេះ មានដូចជា Tillsupper, Filliar , Amitatop ដែលថ្នាំទាំងនេះអាចរកទិញបាននៅតាមទីផ្សារ។

✓ **ការកាត់ពូជលាយ:** គឺជាដំណើរការកាត់ចេញនូវដើមស្រូវណា ដែលគេមើលឃើញថា មានលក្ខណៈប្លែកពីគេ (Phenotype) តាមរយៈភ្នែកទទេ។ ស្មៅចង្រៃ និងដំណាំផ្សេងៗទៀតក៏អាចកាត់ចេញ នៅពេលកាត់ពូជលាយផងដែរ។ លក្ខណៈខុសគ្នា ដែលគេអាចកំណត់ថាជាពូជលាយមានដូចជា កំពស់ដើម ពណ៌របស់ដើម ទំហំស្លឹក លក្ខណៈរូបរាងនៃគ្រាប់ ទំរង់ស្លឹកទង់ជ័យ ពេលវេលាចេញផ្កា ប្រវែងកួរ និងការតំរៀបគ្រាប់ក្នុងកួរ ។ល។ ការកាត់ពូជលាយ មានសារៈសំខាន់ណាស់ក្នុងផលិតកម្មគ្រាប់ពូជ ព្រោះវាជាយន្តការមួយដែលអាចកាត់បន្ថយភាពមិនសុទ្ធរបស់គ្រាប់ពូជបានមួយកំរិតធំ។ ការកាត់ពូជលាយគួរធ្វើឡើងចំនួន ៣ដង គឺ **នៅដំណាក់កាលបែកគុម្ព ចេញកួរ-ផ្កា និងដំណាក់កាលទុំ**។ ពេលវេលាដ៏ល្អប្រសើរបំផុតនោះ គឺដំណាំស្រូវកំពុងចេញកួរចេញផ្កា និងពេលមុនច្រូត ១សប្តាហ៍ ព្រោះគេអាចមើលឃើញភាពខុសគ្នាយ៉ាងច្បាស់តាមរយៈកួរ និងកំពស់ដើម។

## ៣.៤ ការគ្រប់គ្រងនៅពេល ឬក្រោយពេលប្រមូលផល

### - ការប្រមូលផល

គុណភាពគ្រាប់ពូជ និងភាគរយនៃការបាត់បង់គ្រាប់នៅពេលប្រមូលផល គឺមានទំនាក់ទំនងជាមួយនឹងពេលវេលានៃការប្រមូលផល។ សំរាប់ផលិតកម្មគ្រាប់ពូជ ដំណាំស្រូវត្រូវច្រូតនៅពេលដែលសំណើមគ្រាប់ពី **២០-២៥% ឬភាគរយគ្រាប់ទុំពី ៨៥-៩០% (ពណ៌លឿង)** ហើយគ្រាប់ដែលនៅគល់កួរដាក់ម្សៅឡើងរឹង គឺប្រហែល ៣០ថ្ងៃក្រោយស្រូវចេញកួរចេញផ្កា។ ប្រសិនបើប្រមូលផលនៅពេលស្រូវទុំជ្រុល អាចធ្វើឱ្យមានការបាត់បង់ច្រើននៅពេលប្រមូលផល ហើយម្យ៉ាងធ្វើឱ្យគ្រាប់អង្ករឡើងប្រេះ នៅពេលបោកបែន។ ប្រសិនបើប្រមូលផលស្រូវពេលមិនទាន់ទុំល្អ ក៏ធ្វើឱ្យគុណភាពគ្រាប់ស្រូវមិនល្អផងដែរ ព្រោះគ្រាប់អង្ករនៅសពោះ និងមានរាងស្រាវ។ **តើការប្រមូលផលគួរច្រូតកាត់ បោកបែនស្រូវពូជ តម្រូវឱ្យធ្វើដោយកំលាំងមនុស្ស ឬយ៉ាងណា?** ចម្លើយគឺថា ការច្រូតកាត់ បោកបែនដោយកំលាំងមនុស្ស គឺមានលក្ខណៈល្អប្រសើរ

គឺម្ចាស់ស្រែអាចដកចេញនូវដើមណាដែល លាយនៅពេលច្រូត ហើយម្យ៉ាងការបោកបែនមិនធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់គ្រាប់អង្ករ។ តែការច្រូតបោកបែនដោយកំលាំងមនុស្ស ត្រូវការចំណាយកំលាំងពលកម្មច្រើន។ បច្ចុប្បន្នដោយសារការប្រើប្រាស់គ្រឿងយន្តមានកាន់តែច្រើន កសិករកម្រនឹងច្រូត និងបោកបែនដោយកំលាំងមនុស្សសុទ្ធសាធណាស់ ពោលគឺកសិករមួយចំនួនច្រូតដោយកំលាំងមនុស្ស ហើយបោកដោយម៉ាស៊ីន និងកសិករមួយចំនួនប្រើប្រាស់ម៉ាស៊ីន (Combine)តែម្តង។ ការប្រើប្រាស់ម៉ាស៊ីនបោក និងម៉ាស៊ីន ក៏អាចធ្វើទៅបាន សំរាប់ផលិតកម្មគ្រាប់ពូជ តែត្រូវការការប្រុងប្រយ័ត្នខ្ពស់ ដោយសារនៅក្នុងម៉ាស៊ីនតែងមានសល់គ្រាប់ស្រូវផ្សេង មុនពេលមកច្រូតស្រូវផលិតពូជ។ ***ជាការប្រុងប្រយ័ត្ន គឺយើងត្រូវច្រូតឬបោកស្រូវមួយចំនួនចោលជាមុនសិន***។ មានមតិមួយចំនួនលើកឡើងថា **ការប្រើ ប្រាស់ម៉ាស៊ីន ឬបោកដោយម៉ាស៊ីនធ្វើឱ្យគ្រាប់អង្ករខូច តើអ្នកយល់យ៉ាងដូចម្តេច?** ជាការពិត ប្រសិនបើយើងច្រូត រួចហាលយូរពេកមុននឹងបោក ឬទុកឱ្យស្រូវក្នុងស្រែទុំជ្រុល ហើយបោកបែនដោយម៉ាស៊ីនអាចប៉ះពាល់ដល់គ្រាប់។ ត្រង់ចំណុចនេះ បើចង់ច្រូតកាត់និងបោកបែនដោយគ្រឿងចក្រ យើងគប្បីកុំទុកស្រូវឱ្យទុំពេក និងកុំច្រូតហាលថ្ងៃយូរពេក មុននឹងបញ្ចូលក្នុង ម៉ាស៊ីនបោក។

**- ការហាលសំងួតគ្រាប់ពូជ**

ដើម្បីកុំឱ្យបាត់បង់គុណភាពគ្រាប់ពូជ កសិករគប្បីហាលសំងួតភ្លាមបន្ទាប់ពីច្រូតរួច ព្រោះវាធ្វើឱ្យសំបុរគ្រាប់ភ្លឺថ្លាល្អ។ គុណភាពគ្រាប់ពូជក៏អាចទាក់ទងផងដែរ ជាមួយនឹងវិធីសាស្ត្រសំងួត។ មានវិធីសាស្ត្រសំងួតស្រូវ ២ បែប គឺហាលដោយកំដៅថ្ងៃ និងសំងួតដោយឡសំងួត។ ការហាលដោយពន្លឺថ្ងៃ គឺមានគុណភាពល្អ ប្រសិនបើយើងមានកំលាំងពលកម្មគ្រប់គ្រាន់សំរាប់ហាលឱ្យបានជាប្រចាំ។ ការហាលស្រូវពូជដោយពន្លឺថ្ងៃ គឺត្រូវប្រមូលជាពំនូក និងគ្របនៅពេលកំដៅថ្ងៃខ្លាំង (ម៉ោង ១២ ដល់ម៉ោង ១រសៀល) ហើយអាចពង្រាយហាលឡើងវិញនៅម៉ោង ២ រសៀល ពេលកំដៅថ្ងៃថយចុះ។ បច្ចុប្បន្ន ដោយសារបញ្ហាភ្លៀងច្រើន និងខ្វះពន្លឺ ក្នុងផលិតកម្មគ្រាប់ពូជមិនអាចពឹងទាំងស្រុងលើធម្មជាតិទៀតឡើយ គឺគេអាចសំងួតដោយឡសំងួតចាក់ធា (Flat bed dryer) ឬឡសំងួតបែបទំនើប (Circulation dryer)។ ការសំងួតដោយឡសំងួត ជាពិសេស(Flat bed dryer) អាចជួបប្រទះនឹងបញ្ហាមួយចំនួនដូចជា ពិបាកកំណត់កំដៅក្នុងឡមិនឱ្យក្តៅខ្លាំងពេក និងពិបាកកើបចូល និងកើបចេញពីឡ ។ តែចំពោះឡសំងួតបែបទំនើប គឺមានលក្ខណៈល្អបំផុតចំពោះផលិតគ្រាប់ពូជទ្រុងទ្រាយធំ។ ជាទូទៅសំណើមគ្រាប់ស្រូវដែលល្អសំរាប់ស្តុក គឺចន្លោះពី ១២-១៤%។ ចំពោះការហាលដោយកំដៅថ្ងៃ កសិករគួរប្រុងប្រយ័ត្ន ការហាលស្រូវពូជច្រើនមុខក្បែរគ្នា ព្រោះវាមានឱកាសច្រើនក្នុងការលាយ ដោយសារសត្វរត់កាត់ ខ្យល់បក់ខ្លាំង (ខ្យល់គួច) ឬការបាចស្រូវពូជបញ្ចូលគ្នាដោយសារកូន ក្មេងលេង។ ដូច្នេះ ដើម្បីការពារ យើងត្រូវគ្របស្បៃលើ ទីលានហាលស្រូវនីមួយៗ ជាដាច់ខាត។

**- ការបក់សំអាត និងការវេចខ្ចប់គ្រាប់ពូជ**

ការបោកស្រូវដោយដៃឬម៉ាស៊ីនក្តី តែងបន្សល់ទុកនូវកំទេចកំទីផ្សេងៗដូចជា កំទេចចំបើង ស្មៅស្រូវ កំទេចដុំដី គ្រួស ថ្ម និងសំដី។ ការបក់សំអាតគួរធ្វើឡើងនៅមុនពេលយកស្រូវពូជទៅស្តុក ព្រោះថាកំទេចកំទី និងសំដីស្រូវ អាចស្រូបយកសំណើមពីបរិយាកាស ជាហេតុធ្វើឱ្យប៉ះពាល់ដល់គុណភាពគ្រាប់ពូជស្រូវ។ វិធីសាស្ត្រសាមញ្ញតាមបែបបុរាណ ការសំអាត

គ្រាប់ពូជស្រូវ ធ្វើតាមរយៈការរោយ ដោយខ្យល់ធម្មជាតិឬប្រើប្រាស់កង្ហារជំនួយ។ ការប្រើប្រាស់វិធីសាស្ត្រនេះ គឺអាចយកចេញបានតែកំទេចកំទីស្រាលៗតែប៉ុណ្ណោះ ហើយជាទូទៅវាមិនបានស្អាតល្អទេ។

បច្ចុប្បន្ន មានការកែច្នៃឧបករណ៍បក់ និងរែងសំអាតគ្រាប់ពូជច្រើនបែប ដូចជា ការច្នៃម៉ាស៊ីនបោកស្រូវ ការច្នៃដោយប្រើអាគុយ និងការច្នៃដោយប្រើម៉ាស៊ីនរោយនឹងរែងគ្រាប់ស្រូវ។ ប្រសិនបើយើងមានគ្រាប់ពូជច្រើន ហើយមានបំណងលក់ប្រកួតប្រជែងលើទីផ្សារ កសិករគួរតែប្រើប្រាស់ឧបករណ៍ច្នៃមានទាំងរោយ និងរែង សំរាប់សំអាត។

**- ការរក្សាទុកគ្រាប់ពូជ**

ការទុកដាក់ស្រូវពូជបានល្អ គឺធ្វើឱ្យស្រូវពូជរក្សាគុណភាពបានយូរ និងដោយសុវត្ថិភាព ។ មុននឹងយកស្រូវពូជទៅទុក កសិករគប្បីគិតគូរអំពីសំណើមគ្រាប់ ភាពគត់ម្មត់នៃឃ្លាំង ការវេចខ្ចប់ និងការតំរៀបបាវស្រូវពូជ។ ជាធម្មតា ការរក្សាស្រូវពូជរបស់កសិករក្នុងទ្រង់ទ្រាយតូច មានដូចជា ការដាក់ក្នុងបាវ ដាក់ក្នុងធុងសាំង ដាក់ក្នុងពាង និងមួយចំនួនតូចចងព្យួរកួរស្រូវតែម្តង។ សម្រាប់ការរក្សាទុកក្នុងទ្រង់ទ្រាយធំ កសិករត្រូវមានឃ្លាំង ឬជង្រុក ដែលមានជញ្ជាំងនិងតំបូលជិតល្អ និងមានកំណល់ត្រឹមត្រូវ។ ចំពោះការតំរៀបស្រូវពូជក្នុងឃ្លាំង គឺចៀសវាងគរខ្ពស់ពេក ដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ដំណុះគ្រាប់ដែលនៅខាងក្រោមៗ (ណែនពេក ខ្វះអុកស៊ីសែន)។ ការប្រើប្រាស់ថង់ផ្លាស្ទិកក្នុងបាវ ឬប្រើប្រាស់សំបកបាវដែលមានស្រោបផ្លាស្ទិក នឹងអាចជួយរក្សាគុណភាពស្រូវពូជបានយូរ (កាត់បន្ថយការឡើងចុះសំណើមតាមបរិយាកាសខាងក្រៅ)។ ដើម្បីងាយស្រួលក្នុងការ លើកដាក់ និងលក់ដូរ កសិករគួរច្រករក្សាគ្រាប់ពូជមិនឱ្យលើសពី ៥០គក្រ ក្នុងមួយបាវ។ ក្នុងករណីមានពូជស្រូវច្រើនប្រភេទដាក់ក្នុងឃ្លាំងតែមួយ កសិករគប្បីសរសេរផ្លាកលើបាវ ឬប្រើប្រាស់បាវខុសៗគ្នា ដើម្បីងាយស្រួលចំណាំ និងចៀសវាងច្រឡំគ្នា។ ការរក្សាគ្រាប់ពូជក្នុងឃ្លាំង កសិករត្រូវតែឧស្សាពិនិត្យ ជាពិសេសលើវត្តមានសត្វខ្មូត។ ប្រសិនបើឃើញមានវត្តមានសត្វខ្មូត កសិករគប្បីហាល ស្រូវពូជឡើងវិញ ឬប្រើប្រាស់ថ្នាំពុលប្រភេទឧស្ម័ន (Fumigation ) ដើម្បីកំចាត់តែម្តង។